ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០០៣/២៦-ហ្គ្រេត ញូ វីង ហ្គាម៉ុន (ខេមបូឌា) ឯ.ក

កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៦

សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **សេង រួចហ៊ុន**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **លីវ សុវណ្ណា**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

តាគីនៃវិវាទ

១- តាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ហ្គ្រេត ញូ វីង ហ្គាម៉ុន (ខេមបូឌា) ឯ.ក**

អាសយដ្ឋាន ៖ ភូមិឃុលចេក ឃុំជីខ្មា ស្រុកទ្រាំង ខេត្តតាកែវ

ទូរស័ព្ទ ៖ ០៧១ ៧២ ៧៥ ១៣៥ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមសវនាការ ៖

១- លោកស្រី	អកស	ប្រធានរដ្ឋបាល
២- លោកស្រី	មសក	ជំនួយការរដ្ឋបាល
៣- លោកស្រី	សល	ជំនួយការរដ្ឋបាល

២- តាគីកម្មករនិយោជិត

ឈ្មោះ ៖ **តាគីតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងារមួយ នៃក្រុមហ៊ុន ហ្គ្រេត ញូ វីង ហ្គាម៉ុន (ខេមបូឌា) ឯ.ក**

អាសយដ្ឋាន ៖ ភូមិឃុលចេក ឃុំជីខ្មា ស្រុកទ្រាំង ខេត្តតាកែវ

ទូរស័ព្ទ ៖ ០១៦ ៩១៨ ១៦៨ /០៧១ ៣០៣៥ ៥៣៨ ទូរសារ ៖ គ្មាន

តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ ៖

១- លោក	សស	ជានសហព័ន្ធសហជីពការងារដើម្បីកម្មករ (LFUC)
២- លោកស្រី	ផសវ	ជានសហជីពមូលដ្ឋាន
៣- លោក	មរណ	អនុប្រធានសហជីពមូលដ្ឋាន
៤-លោក	ហបហ	លេខាធិការសហជីពមូលដ្ឋាន

បញ្ហាកុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- តំណាងកម្មករនិយោជិតស្នើសុំឱ្យក្រុមហ៊ុនសងជួសការឈប់សម្រាកប្រចាំឆ្នាំចំនួន ២ថ្ងៃ (គឺនៅថ្ងៃទី៥ និងទី៦ ខែមករា ឆ្នាំ២០២៦) ដែលក្រុមហ៊ុនមិនមានការងារឱ្យកម្មកររធ្វើ សូមសងត្រឡប់មកវិញ។

តំណាងកម្មករបានបញ្ជាក់លើការទាមទារថា៖ កម្មកនិយោជិតដែលបំពេីការងារនៅក្នុងក្រុមហ៊ុន ទោះបីជាធ្វើការមិនទាន់បាន ១ឆ្នាំក៏ដោយ តែក្រុមហ៊ុនបានជួយសម្រួល និងផ្តល់នូវលក្ខណៈពិសេសជូនបងប្អូនកម្មកនិយោជិត ដោយផ្តល់សិទ្ធិប្រើប្រាស់ច្បាប់ឈប់សម្រាកប្រចាំឆ្នាំ ១៨ថ្ងៃមុនបាន (ដោយមិនដាច់ប្រាក់ឈ្នួលប្រចាំថ្ងៃ រួមទាំងអត្ថប្រយោជន៍) និងមិនមានការកាត់កងទៅនឹងឆ្នាំបន្ទាប់នោះទេ។

កម្មកនិយោជិតបានទទួលស្គាល់ថានៅក្នុងខែមករា (ថ្ងៃទី៥ និងទី៦) ឆ្នាំ២០២៦ ក្រុមហ៊ុនបានឱ្យកម្មកមួយចំនួនឈប់សម្រាកចំនួន ២ថ្ងៃ (មូលហេតុគ្មានការងារធ្វើគ្រប់គ្រាន់) ដោយរៀបចំដោះដូរច្បាប់ឈប់សម្រាកប្រចាំឆ្នាំ ដែលក្រុមហ៊ុនផ្តល់ជាលក្ខណៈពិសេស ជូនកម្មកនិយោជិតប្រើមុនបាន ដោយមិនកាត់ប្រាក់ឈ្នួលប្រចាំថ្ងៃ រួមទាំងអត្ថប្រយោជន៍ នៅរក្សាជូនដដែល នៅថ្ងៃគ្មានការងារធ្វើនោះ។

កម្មកនិយោជិតយល់ឃើញថាអ្វីដែលក្រុមហ៊ុនជួយសម្រួលផ្តល់ជាលក្ខណៈពិសេសមុននោះវាល្អប្រសើរជាងច្បាប់ តែពេលមានបញ្ហាអត់ការងារធ្វើ បែរជារៀបចំឱ្យឈប់សម្រាកដោយដោះដូរ តែគ្មានបាត់បង់អត្ថប្រយោជន៍។

កម្មករបានបញ្ជាក់បន្ថែមទៀតថា នៅក្នុងខែមករា (ថ្ងៃទី៥ និងទី៦) ឆ្នាំ២០២៦ កម្មកដែលបានឈប់សម្រាកនៅថ្ងៃនោះ គឺមិនមានការបាត់បង់ប្រាក់ឈ្នួល ឬខូចខាតអត្ថប្រយោជន៍ណាមួយឡើយ។

កម្មកនិយោជិតនៅរក្សាជំហរទាមទារ សូមឱ្យក្រុមហ៊ុនសងថ្ងៃឈប់សម្រាក២ថ្ងៃ ដែលបានកាត់ជូនមកកម្មកដែលបានផ្តិតមេដៃទាមទារវិញ។

ដោយឡែកតំណាងនិយោជក ជាការគីចុងចម្លើយបញ្ជាក់ថា គ្រប់កម្មកនិយោជិតដែលចូលបម្រើការងារទាំងអស់ គឺក្រុមហ៊ុនជួយសម្រួល ផ្តល់នូវអតិភាពពិសេសដល់កម្មកគ្រប់គ្នា ដោយផ្តល់សិទ្ធិពិសេសក្នុងការប្រើប្រាស់ច្បាប់ឈប់សម្រាកប្រចាំឆ្នាំ ១៨ថ្ងៃ មុនបំពេញការងារគ្រប់១ឆ្នាំ និងមិនមានការកាត់កងទៅនឹងឆ្នាំបន្ទាប់នោះទេ។

នៅដើមខែមករា (ថ្ងៃទី៥ និងទី៦) ឆ្នាំ២០២៦ ក្រុមហ៊ុនមិនមានការងារធ្វើគ្រប់គ្រាន់ ដោយរៀបចំអនុញ្ញាតឱ្យកម្មកតាមផ្នែកខ្លះ ដែលខ្វះសម្ភារៈធ្វើបន្ត ឈប់សម្រាកដោយរក្សាប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗនៅដដែល ពុំមានការបាត់បង់ផលប្រយោជន៍របស់កម្មកនិយោជិតនោះទេ។

ចំពោះការសូមឱ្យសងត្រឡប់ចំនួន២ថ្ងៃវិញនោះ គឺក្រុមហ៊ុនបានអនុវត្តលក្ខខណ្ឌល្អប្រសើរជាងច្បាប់ក្នុងការជួយសម្រួលដល់កម្មកនិយោជិត ដោយពុំមានការបាត់បង់អត្ថប្រយោជន៍ណាមួយឡើយ ដូចនេះសូមឱ្យកម្មកយល់ពីបំណងជួយរបស់ក្រុមហ៊ុនកន្លងមក។

អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី៣ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលត្រូវបាន

ឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៨៥/២០ ក.ប/ប្រ.ក.វ. ក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ (អាណត្តិទី១៨)។

ការព្យាយាមផ្សះផ្សាវិវាទការងារួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងារួមនៃក្រុមហ៊ុន ហ្គ្រេត ញូ រីង ហ្គាម៉ុន (ខេមបូឌា) ឯ.ក លេខ ២១៤ ក.ប/អក/វក ចុះថ្ងៃសុក្រ ២កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៦ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៦។

សវនាការ និង សន្ទេបនីតិវិធី

ទីកន្លែងសវនាការ ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល "ជាន់ទី១៨" នៃអាគារស្នាក់ការកណ្តាល បេឡាជាតិសន្តិសុខសង្គម (ប.ស.ស) ស្ថិតនៅផ្លូវបេតុង ភូមិសំរោង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

កាលបរិច្ឆេទសវនាការ ៖ ថ្ងៃព្រហស្បតិ៍ ១៥កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ត្រូវនឹងថ្ងៃទី២ ខែមេសា ឆ្នាំ២០២៦ វេលាម៉ោង ២ និង ០០ នាទី រសៀល។

បញ្ហានីតិវិធី ៖

នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៦ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្តឹងរបស់កម្មការនិយោជិតនៃក្រុមហ៊ុន ហ្គ្រេត ញូ រីង ហ្គាម៉ុន (ខេមបូឌា) ឯ.ក ស្តីពីការស្នើសុំឱ្យដោះស្រាយនូវលក្ខខណ្ឌការងារចំនួន ១៥ចំណុច។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងនេះរួចមក និងផ្អែកតាមលិខិតបង្គាប់ការលេខ ០២០ ក.ប/លប/នវក អ្នកផ្សះផ្សាបានពិនិត្យសំណុំរឿងនេះផ្អែកតាមនីតិវិធីច្បាប់ និងបានធ្វើការផ្សះផ្សានៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៦ ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ១៤ចំណុច។ ចំណុចមិនសះជាចំនួន ១ចំណុច ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៦ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងារួមនៃក្រុមហ៊ុន ហ្គ្រេត ញូ រីង ហ្គាម៉ុន (ខេមបូឌា) ឯ.ក លេខ ២១៤ ក.ប/អក/វក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៦។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៦។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញភាគីនិយោជក និងភាគីកម្មការនិយោជិតមកសវនាការនៅថ្ងៃ៣០ ខែមីនា ឆ្នាំ២០២៦ វេលាម៉ោង ៨ និង ៣០ នាទីព្រឹក។ យ៉ាងណាមិញ ភាគីនិយោជកបានដាក់លិខិតចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៦ ស្នើសុំលើកពេលសវនាការ ពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៦ ទៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៦ ដោយមូលហេតុ ក្រុមហ៊ុនមានភ្ញៀវចុះមកអូឌីត (សវនកម្ម) នៅថ្ងៃទី២៦, ៣០ និង ៣១ ខែមីនា និងថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៦។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញពីភាពចាំបាច់ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសម្រេចលើកពេលសវនាការពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៦ វេលាម៉ោង ៨ និង ៣០ នាទីព្រឹក ទៅថ្ងៃទី២ ខែមេសា ឆ្នាំ២០២៦ វេលាម៉ោង ២ និង ០០ នាទីរសៀល វិញ។ ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួរកេនូវអង្គហេតុផ្សេងៗ និងបានធ្វើការផ្សះផ្សាលើចំណុចវិវាទនេះបន្ថែមទៀត ប៉ុន្តែមិនទទួលបានលទ្ធផលសះជានឹងគ្នានោះទេ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាលើចំណុចវិវាទចំនួន ១ចំណុចនេះ។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

ភាគីទាំងពីរបានឯកភាពពន្យារកាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល ពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៦ ទៅយ៉ាងយូរ ត្រឹមថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៦ វិញ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិាទខាងលើនេះ ដោយផ្អែកលើកស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

កស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ (គ្មាន)

ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលទទួលបាន

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៦ របស់ក្រុមហ៊ុនហ្គ្រេត ញូ វីង ហ្គាម៉ុន (ខេមបូឌា) ឯ.ក គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពី សំណើរសុំពន្យាពេលសវនាការសំណុំរឿងលេខ ០០៣/២៦ ក្រុមហ៊ុន ហ្គ្រេត ញូ វីង ហ្គាម៉ុន (ខេមបូឌា) ឯ.ក។

២- លិខិតចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០២៦ របស់លោក YRJ ជានាយកក្រុមហ៊ុន ហ្គ្រេត ញូ វីង ហ្គាម៉ុន (ខេមបូឌា) ឯ.ក គោរពជូន ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំផ្ទេរសិទ្ធិជូនលោកស្រី អកស ជាប្រធានរដ្ឋបាល ដែលមានសិទ្ធិ និងអំណាចពេញលេញក្នុងការដោះស្រាយរាល់បញ្ហាវិាទការងារ ក្នុងនាមតំណាងឱ្យម្ចាស់ ឬនាយកក្រុមហ៊ុន ព្រមទាំងមានសិទ្ធិសម្រេចរាល់កិច្ចព្រមព្រៀងផ្សេងៗ ដើម្បីទំនាក់ទំនងជាមួយក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងករណីវិាទការងារួមនៅសហគ្រាស ហ្គ្រេត ញូ វីង ហ្គាម៉ុន (ខេមបូឌា) ឯ.ក ក្នុងសំណុំរឿងលេខ ០០៣/២៦។

៣- លិខិតចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៦ របស់ក្រុមហ៊ុន ហ្គ្រេត ញូ វីង ហ្គាម៉ុន (ខេមបូឌា) ឯ.ក សូមគោរពជូន ប្រធានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីការផ្តល់ជូនសារណាសម្រាប់សវនាការដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២ ខែមេសា ឆ្នាំ២០២៦។

៤- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន ហ្គ្រេត ញូ វីង ហ្គាម៉ុន (ខេមបូឌា) ឯ.ក លេខ ពណ.ចបព ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៥។

៥- លក្ខន្តិក:របស់ក្រុមហ៊ុន ហ្គ្រេត ញូ វីង ហ្គាម៉ុន (ខេមបូឌា) ឯ.ក បានតម្កល់ទុកលេខ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៥ នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម។

៦- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ហ្គ្រេត ញូ វីង ហ្គាម៉ុន (ខេមបូឌា) ឯ.ក បានចុះទិដ្ឋាការលេខ អធក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៥ ចេញដោយនាយកដ្ឋានអធិការកិច្ចការងារ។

៧- លិខិតសូមបដិសេធ និងដកខ្លួន ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៦។

៨- កំណត់ហេតុនៃការផ្សះផ្សាវិាទការងារួមនៃក្រុមហ៊ុន ហ្គ្រេត ញូ វីង ហ្គាម៉ុន (ខេមបូឌា) ឯ.ក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៦។

ខ- ឯកសារបានទទួលពីភាគីកម្មការនិយោជិត ៖

១- លិខិតលេខ ០២៧/២៦ ក.ប/វ.ក ចុះថ្ងៃចន្ទ ១៥កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩ ត្រូវនឹងថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៦ របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បញ្ជាក់

ថា សហជីពការងារដើម្បីកម្ពុជាក្រុមហ៊ុន ប្រ្គេត ញូ រីង ហ្គាម៉ុន (ខេមបូឌា) ឯ.ក ជាអង្គការវិជ្ជាជីវៈមួយត្រូវបានចុះបញ្ជីនៅនាយកដ្ឋានវិាទការងារ និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ។

២- វិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈសហជីពការងារដើម្បីកម្ពុជាក្រុមហ៊ុន ប្រ្គេត ញូ រីង ហ្គាម៉ុន (ខេមបូឌា) ឯ.ក លេខ ០៥១/២៦ ក.ប/វ.ប.វ.ក ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៦។

៣- បញ្ជីឈ្មោះកម្មការនិយោជិត។

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ៖

១- របាយការណ៍ស្តីពីការដោះស្រាយវិាទការងាររួមនៃក្រុមហ៊ុន ប្រ្គេត ញូ រីង ហ្គាម៉ុន (ខេមបូឌា) ឯ.ក លេខ ២១៤ ក.ប/អក/វក ចុះថ្ងៃសុក្រ ២កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៦។

២- កំណត់ហេតុនៃការផ្សះផ្សាវិាទការងាររួមនៃក្រុមហ៊ុន ប្រ្គេត ញូ រីង ហ្គាម៉ុន (ខេមបូឌា) ឯ.ក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៦។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មការនិយោជិតក្នុងការដោះស្រាយវិាទការងាររួមនៃក្រុមហ៊ុន ប្រ្គេត ញូ រីង ហ្គាម៉ុន (ខេមបូឌា) ឯ.ក លេខ ០០១/២០២៦ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៦ របស់នាយកដ្ឋានវិាទការងារ។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ៖

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ០១៣ កប/អក/វក/លកអ ចុះថ្ងៃអង្គារ ៦កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៦។

២- លិខិតអញ្ជើញភាគីកម្មការនិយោជិតចូលរួមសវនាការ លេខ ០១៤ កប/អក/វក/លកអ ចុះថ្ងៃអង្គារ ៦កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៦។

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ០១៦ កប/អក/វក/លកអ ចុះថ្ងៃសុក្រ ៩កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៦។

៤- លិខិតអញ្ជើញភាគីកម្មការនិយោជិតចូលរួមសវនាការ លេខ ០១៧ កប/អក/វក/លកអ ចុះថ្ងៃសុក្រ ៩កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៦។

អន្តហេតុ

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មការនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុន ប្រ្គេត ញូ រីង ហ្គាម៉ុន (ខេមបូឌា) ឯ.ក មានសកម្មភាពចម្បងផ្នែកកាត់ដេរសម្លៀកបំពាក់ និងមានជួលកម្មការនិយោជិតសរុបចំនួន ៩៤៦នាក់ (ស្រីចំនួន ៦៦៨នាក់) *(យោងតាមរបាយការណ៍ស្តីពីការដោះស្រាយវិាទការងាររួមនៃក្រុមហ៊ុន ប្រ្គេត ញូ រីង ហ្គាម៉ុន (ខេមបូឌា) ឯ.ក លេខ ២១៤ ក.ប/អក/វក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៦)*

- នាយកដ្ឋានវិវាទការងារបានចេញលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មកររនិយោជិតក្នុងការដោះស្រាយវិវាទការងារួមលេខ ០០១/២០២៦ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៦ ដែលមានកម្មកររនិយោជិត ចំនួន ៤នាក់ រួមមាន ៖ ១. លោកស្រី ផសវ ២. លោក មណ ៣. លោក ហបហ , និង ៤. លោកស្រី កសល
- សហជីពការងារដើម្បីកម្ពុជាឯករាជ្យក្រុមហ៊ុន ប្រ្គេត ញូ រីង ហ្គាម៉ិន (ខេមបូឌា) ឯ.ក ទទួលបានវិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈ ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លេខ ០៥១/២៦ ក.ប/វ.ប.វ.ក ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៦ និងលិខិតទទួលស្គាល់ថ្នាក់ដឹកនាំសហជីពលេខ ០២៧/២៦ ក.ប/វ.ក ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៦ ដែលមានថ្នាក់ដឹកនាំសហជីពចំនួន ៣នាក់ រួមមាន ៖ ១. លោកស្រី ផសវ ជាប្រធាន, ២. លោក មណ ជាអនុប្រធាន និង ៣. លោក ហបហ ជាលេខាធិការ។
- ឯកសារបឋមចម្លងបញ្ជីឈ្មោះកម្មកររនិយោជិតដែលបានផ្តិតស្នាមម្រាមដៃទាមទារនៅក្នុងលិខិតស្នើសុំ និងចាត់តាំងប្រតិភូចរចា ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៦ ដែលភ្ជាប់ជាមួយរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងារួមនៃក្រុមហ៊ុន ប្រ្គេត ញូ រីង ហ្គាម៉ិន (ខេមបូឌា) ឯ.ក មានបញ្ជីឈ្មោះ និងស្នាមម្រាមដៃកម្មកររនិយោជិតសរុបចំនួន ៦៤នាក់។

ចំណុចវិវាទ ៖ ភាគីកម្មកររនិយោជិតទាមទារឱ្យនិយោជកសងជួសការឈប់សម្រាកប្រចាំឆ្នាំចំនួន ២ថ្ងៃ (គឺនៅថ្ងៃទី៥ និងទី៦ ខែមករា ឆ្នាំ២០២៦) ដែលក្រុមហ៊ុនមិនមានការងារឱ្យកម្មកររនិយោជិតធ្វើ សូមសងត្រឡប់មកវិញ

- ភាគីកម្មកររនិយោជិតបញ្ជាក់ការទាមទារឱ្យនិយោជកសងវិលឹកការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលចំនួន ២ថ្ងៃ គឺនៅថ្ងៃទី៥ និងទី៦ ខែមករា ឆ្នាំ២០២៦ ដែលនិយោជកមិនមានការងារឱ្យកម្មកររនិយោជិតធ្វើ ជូនកម្មកររនិយោជិតចំនួន ១៨នាក់។
- ភាគីទាំងពីរទទួលស្គាល់ថា ៖
  - ការអនុវត្តនៅក្នុងក្រុមហ៊ុន នៅពេលដែលចប់កិច្ចសន្យាការងារសោកល្បងរយៈពេល ២ខែ កម្មកររនិយោជិតអាចប្រើប្រាស់ការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលបាន ដោយពួកគាត់ត្រូវស្នើសុំទៅផ្នែករដ្ឋបាល ឬប្រធានផ្នែក មុនថ្ងៃឈប់សម្រាកចំនួន ១ថ្ងៃ។
  - នៅថ្ងៃទី៣ ឬទី៤ ខែមករា ឆ្នាំ២០២៦ និយោជកបានប្រជុំជាមួយប្រធានផ្នែក និងតំណាងកម្មកររនិយោជិត អំពីការអនុញ្ញាតឱ្យកម្មកររនិយោជិតឈប់សម្រាកដោយប្រើប្រាស់ការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលចំនួន ២ថ្ងៃ គឺនៅថ្ងៃទី៥ និងទី៦ ខែមករា ឆ្នាំ២០២៦ នៅពេលដែលនិយោជកមិនមានការងារឱ្យកម្មកររនិយោជិតធ្វើសម្រាប់ក្រុមដេរលេខ ៧, ៨, ១០, ១២, ១៤, និង ១៦។ បន្ទាប់មក ប្រធានផ្នែក និងតំណាងកម្មកររនិយោជិត បានប្រជុំជូនដំណឹងបន្តទៅកម្មកររនិយោជិតតាមផ្នែកវៀងៗខ្លួន ប៉ុន្តែមិនមានលិខិតជាលាយលក្ខណ៍អក្សរឱ្យកម្មកររនិយោជិតចុះហត្ថលេខាយល់ព្រមនោះទេ។
  - ទោះបីជាយ៉ាងណាក៏ដោយ នៅថ្ងៃទី៥ និងទី៦ ខែមករា ឆ្នាំ២០២៦ មានកម្មកររនិយោជិតមួយចំនួនបានមកធ្វើការធម្មតា ដែលក្នុងនោះក៏មានកម្មកររនិយោជិតនៅក្រុមដេរលេខ ១៤ និងលេខ ១៦ ដែលត្រូវបានប្រធានក្រុមជ្រើសរើសម្នាក់ ឬពីរនាក់ ឱ្យទៅជួយក្រុមដេរផ្សេងផងដែរ។
- ភាគីកម្មកររនិយោជិតបញ្ជាក់មូលហេតុនៃការទាមទារថា ៖

ARBITRATION COUNCIL

- ការប្រជុំជូនដំណឹងបន្តរបស់ប្រធានផ្នែក និងតំណាងកម្មករនិយោជិតអំពីការអនុញ្ញាតឱ្យកម្មករនិយោជិតឈប់សម្រាកដោយប្រើប្រាស់ការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលចំនួន ២ថ្ងៃ គឺនៅថ្ងៃទី៥ និងទី៦ ខែមករា ឆ្នាំ២០២៦ បានធ្វើឡើងនៅចុងម៉ោងការងាររបស់កម្មករនិយោជិត។ ហេតុនេះ កម្មករនិយោជិតមិនមានពេលក្នុងការតវ៉ាឱ្យមានដំណោះស្រាយនោះទេ។
- ការអនុវត្តរបស់និយោជកឱ្យកម្មករនិយោជិតឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល នៅពេលដែលនិយោជកមិនមានការងារឱ្យកម្មករនិយោជិតធ្វើ គឺមិនត្រឹមត្រូវនោះទេ ព្រោះថានិយោជកមានសិទ្ធិកាត់ការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលនេះ នៅពេលដែលកម្មករនិយោជិតឈប់សម្រាកពិសេសតែប៉ុណ្ណោះ។
- យោងតាមច្បាប់ស្តីពីការងារ ប្រសិនបើក្រុមហ៊ុនមិនមានការងារឱ្យកម្មករនិយោជិតធ្វើ នោះនិយោជកត្រូវស្នើសុំព្យួរកិច្ចសន្យាការងារស្របតាមនីតិវិធីច្បាប់។

- ភាគីនិយោជកមិនអាចផ្តល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិតបានទេ ដោយមូលហេតុថា ៖
  - មិនមានការតវ៉ាណាមួយពីកម្មករនិយោជិត នៅពេលដែលប្រធានផ្នែក និងតំណាងកម្មករនិយោជិតប្រជុំជូនដំណឹងបន្តទៅកម្មករនិយោជិតតាមផ្នែករៀងៗខ្លួន អំពីការអនុញ្ញាតឱ្យប្រើប្រាស់ការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលចំនួន ២ថ្ងៃ គឺនៅថ្ងៃទី៥ និងទី៦ ខែមករា ឆ្នាំ ២០២៦ នៅពេលដែលមិនមានការងារធ្វើនោះទេ។
  - ម្យ៉ាងទៀត ការអនុវត្តរបស់និយោជកដែលអនុញ្ញាតឱ្យកម្មករនិយោជិតប្រើប្រាស់ការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល មុនពេលកម្មករនិយោជិតធ្វើការបានមួយឆ្នាំ គឺជាការអនុវត្តដែលមានលក្ខណៈប្រសើរជាងច្បាប់។ អាស្រ័យហេតុនេះ ចំពោះការអនុញ្ញាតឱ្យកម្មករនិយោជិតឈប់សម្រាកដោយប្រើប្រាស់ការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល នៅពេលដែលនិយោជកមិនមានការងារឱ្យកម្មករនិយោជិតធ្វើ គឺជាសិទ្ធិចាត់ចែងរបស់និយោជក។
  - បន្ថែមលើសពីនេះ ការអនុវត្តរបស់ក្រុមហ៊ុនផ្សេងៗ ដែលនៅក្នុងតំបន់ជាមួយគ្នា គឺនិយោជកបានចាត់ចែងឱ្យកម្មករនិយោជិតឈប់សម្រាក ដោយប្រើប្រាស់ការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល នៅពេលដែលនិយោជកមិនមានការងារឱ្យកម្មករនិយោជិតធ្វើផងដែរ។
- ភាគីកម្មករនិយោជិត និងភាគីនិយោជក បានបញ្ជាក់អំពីចំនួនដើមបណ្តឹងនៅចំណុចវិវាទនេះ ដូចខាងក្រោម ៖
  - ភាគីកម្មករនិយោជិតលើកឡើងថា ៖
    - ការទាមទារនៅក្នុងចំណុចវិវាទនេះ គឺសម្រាប់កម្មករនិយោជិតដែលបានផ្តិតស្នាមម្រាមដៃទាមទារនៅក្នុងលិខិតស្នើសុំ និងចាត់តាំងប្រតិភូចរចា ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៦ ចំនួន ១៦នាក់ និងកម្មករនិយោជិតដែលបានមកចូលរួមសវនាការចំនួន ២នាក់ រួមមានឈ្មោះ ផសវ អត្តលេខ និងឈ្មោះ ហបហ អត្តលេខ សរុបចំនួន ១៨នាក់។
    - ចំពោះកម្មករនិយោជិតដែលបានផ្តិតស្នាមម្រាមដៃនៅក្នុងលិខិតសូមបដិសេធ និងដកខ្លួន ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៦ គឺធ្វើឡើងដោយសារកម្មករនិយោជិតមានការភ័យខ្លាចចំពោះការប្តឹងប្រធានផ្នែករបស់ពួកគាត់។ ម្យ៉ាងទៀត លិខិតសូមបដិសេធ និងដកខ្លួនខាងលើ គឺមានខ្លឹមសារមិនច្បាស់លាស់ដែលអាចភាន់ច្រឡំ និងមិនបានបញ្ជាក់ច្បាស់ថា ជា

ស្នាមម្រាមដៃរបស់កម្មកររនិយោជិតបានប្តឹងបដិសេធនឹងចំណុចវិវាទនេះនោះទេ។ ហេតុនេះ កម្មកររនិយោជិតសូមបដិសេធចំពោះលិខិតបដិសេធ និងដកខ្លួននេះ។

- កាគីនិយោជកលើកឡើងថា ៖
  - បច្ចុប្បន្ននេះ មានកម្មកររនិយោជិតចំនួន ៥៣នាក់ បានសរសេរលិខិតសូមបដិសេធ និងដកខ្លួន ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៦។
  - ផ្អែកតាមបញ្ជីឈ្មោះកម្មកររនិយោជិតចំនួន ១៦នាក់ ដែលបានផ្តិតស្នាមម្រាមដៃទាមទារនៅក្នុងលិខិតស្នើសុំ និងចាត់តាំងប្រតិកូចរចា ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៦ គឺមានឈ្មោះ និងស្នាមម្រាមដៃកម្មកររនិយោជិតចំនួន ១៣នាក់ បានសរសេរលិខិតសូមបដិសេធ និងដកខ្លួន ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៦ ផងដែរ។
  - និយោជកទទួលស្គាល់ថា មានកម្មកររនិយោជិតជាដើមបណ្តឹងនៅសល់ចំនួន ៥នាក់ ប៉ុណ្ណោះ ដោយក្នុងនោះ មានកម្មកររនិយោជិតចំនួន ៣នាក់ មានឈ្មោះនៅក្នុងបញ្ជីឈ្មោះកម្មកររនិយោជិតចំនួន ១៦នាក់ និងកម្មកររនិយោជិតចំនួន ២នាក់ទៀត មានវត្តមានក្នុងសវនាការ។
  - ម្យ៉ាងទៀត លិខិតសូមបដិសេធ និងដកខ្លួន ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៦ គឺធ្វើឡើងដោយកម្មកររនិយោជិតផ្ទាល់ ពោលគឺមិនមានការចូលរួមណាមួយពីកាគីនិយោជកនោះទេ។

- កាគីកម្មកររនិយោជិតបានដាក់បញ្ជីឈ្មោះកម្មកររនិយោជិត ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី២ ខែមេសា ឆ្នាំ២០២៦ មានដូចខាងក្រោម ៖

1		(ស)		ជើរ A16
2		(ស)		ជើរ A16
3		(ប)		ជើរ A16
4		(ស)		ជើរ A16
5		(ស)		ជើរ A16
6		(ស)		ជើរ A16
7		(ស)		ជើរ A16
8		(ស)		ជើរ A16
9		(ស)		ជើរ A16
10		(ស)		ជើរ A16
11		(ស)		ជើរ A16
13		(ស)		ជើរ A16
13		(ស)		ជើរ A16
14		(ប)		ជើរ A14
15		(ស)		ជើរ A14
16		(ស)		ជើរ A14

THE ARBITRATION COUNCIL

- ភាគីនិយោជកបានដាក់លិខិតសូមបដិសេធ និងដកខ្លួន ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៦ ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយមានខ្លឹមសារថា ៖

"យើងខ្ញុំជាកម្មករ ធ្វើការនៅក្រុមហ៊ុន ហ្គ្រេត ញូ ហ្គាម៉ុន (ខេមបូឌា) សូមជំទាស់ចំពោះការធ្វើសកម្មភាពរបស់កម្មករឈ្មោះ A. ផសវ B. មណ C. ហបហ D. ពសឡ ដែលបានអះអាងថា ខ្លួនជាតំណាងឱ្យកម្មកប្រចាំក្រុមហ៊ុន បន្ទាប់មកបានដើរអូសទាញ បោកបញ្ឆោត លួងលោម ឱ្យយើងខ្ញុំចូលរួមសមាជិក ដោយតម្រូវឱ្យផ្តិតមេដៃលើក្រដាសស ដោយគ្មានប្រាប់ពីគោលបំណងឱ្យពិតប្រាកដលើលិខិតថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៦។ ក្រោយមក នៅថ្ងៃទី២១ កុម្ភៈ ឆ្នាំ២០២៦ ស្រាប់តែឈ្មោះ ផសវ មណ បានដើរចេកក្រដាស ហើយនិយាយថាការផ្តិតមេដៃចូលសមាជិកលើកមុន ប្តឹងទាមទារ ១៦ចំណុច គឺកំពុងដោះស្រាយជាមួយក្រុមហ៊ុន។ បន្ទាប់ពីបានមើលលិខិត ស្តាប់ឮបែបនេះ យើងពិតជាហួសចិត្តខ្លាំង ចំពោះទង្វើរបស់គាត់ ដែលបានអូសទាញ បោកបញ្ឆោត លួងលោមប្រមូលយកស្នាមមេដៃរបស់យើងខ្ញុំខុសពីបំណងផ្ទុយពីឆន្ទៈយើងខ្ញុំទាំងស្រុង ដើម្បីតែផលប្រយោជន៍ផ្ទាល់ខ្លួន។

ដូចនេះ យើងខ្ញុំសូមបដិសេធ ដកខ្លួន មិនចូលរួមជាសមាជិក និងការធ្វើសកម្មភាពតាមពួកគាត់ខាងលើទៀត ចាប់ពីថ្ងៃផ្តិតមេដៃនេះតទៅ ហើយ...មិនការបង្ខិតបង្ខំពីខាងណាដែរ។ ការសម្រេចមិនចូលរួមនេះ ដោយសារយើងខ្ញុំត្រូវបានគេបោកបញ្ឆោត យកមេដៃទៅប្រើខុសពីបំណងកម្មករ ហើយអាចបង្កើតឱ្យមានរឿងនៅកន្លែងធ្វើការផងដែរ។

<u>*ស្នាមមេដៃយើងខ្ញុំ*</u>

	ឈ្មោះ	*អត្តលេខ*	*ក្រុម*	*ស្នាមមេដៃ*
1.			*16*	*...*
2.			*16*	*...*
3.			*16*	*...*
4.			*16*	*...*
5.			*16*	*...*
6.			*16*	*...*
7.			*16*	*...*
8.			*16*	*...*
9.			*16*	*...*
10.			*16*	*...*
...			*...*	*...*
13.			*16*	
14.			*16*	
15.			*16*	
53	*...*	*...*	*...*	

- ក្រុមប្រឹក្សាអាជ្ញាកណ្តាលកត់សម្គាល់ឃើញថា ៖
  - ភាគីកម្មកររនិយោជិតបានសរសេរឈ្មោះកម្មកររនិយោជិត សរថ ខុសគ្នា ប៉ុន្តែមានអត្តលេខ ដូចគ្នា ដោយគ្មានការតវ៉ាពីភាគីនិយោជកថាកម្មកររនិយោជិតឈ្មោះ សរថ ជាកម្មកររនិយោជិតខុសគ្នានោះទេ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសន្និដ្ឋានថា ភាគីទាំងពីរសំដៅដល់កម្មកររនិយោជិត សរថ ជាកម្មកររនិយោជិតតែមួយដូចគ្នា ដែលមានអត្តលេខ ។
  - ភាគីទាំងពីរបានសរសេរឈ្មោះកម្មកររនិយោជិត យសន ខុសគ្នា ប៉ុន្តែមានអត្តលេខ G00991 ដូចគ្នា ដោយគ្មានការតវ៉ាពីភាគីណាមួយថាកម្មកររនិយោជិតឈ្មោះ យសន ឬឈ្មោះ យសន ជាកម្មកររនិយោជិតខុសគ្នានោះទេ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសន្និដ្ឋានថា ភាគីទាំងពីរសំដៅដល់កម្មកររនិយោជិត យសន ជាកម្មកររនិយោជិតតែមួយដូចគ្នា ដែលមានអត្តលេខ ។

ហេតុផលនៃសេចក្តីសម្រេច ៖

ចំណុចវិវាទ ៖ ភាគីកម្មកររនិយោជិតទាមទារឱ្យនិយោជកសងរំលឹកការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលចំនួន ២ថ្ងៃ គឺនៅថ្ងៃទី៥ និងទី៦ ខែមករា ឆ្នាំ២០២៦ ដែលនិយោជកមិនមានការងារឱ្យកម្មកររនិយោជិតធ្វើ ជូនកម្មកររនិយោជិតចំនួន ១៨នាក់

នៅក្នុងសវនាការ ភាគីកម្មកររនិយោជិតលើកឡើងថា ការទាមទារនៅក្នុងចំណុចវិវាទនេះសម្រាប់កម្មកររនិយោជិតសរុបចំនួន ១៨នាក់ ដោយក្នុងនោះមានកម្មកររនិយោជិតចំនួន ១៦នាក់ បានផ្តិតស្នាមម្រាមដៃទាមទារនៅក្នុងលិខិតស្នើសុំ និងចាត់តាំងប្រតិភូចរចា ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៦ និងកម្មកររនិយោជិតចំនួន ២នាក់ទៀត បានមកចូលរួមសវនាការ។ ដោយឡែក ភាគីនិយោជកបានលើកឡើងថា ក្នុងបញ្ជីឈ្មោះកម្មកររនិយោជិតចំនួន ១៦នាក់ ដែលបានផ្តិតស្នាមម្រាមដៃទាមទារនៅក្នុងលិខិតស្នើសុំ និងចាត់តាំងប្រតិភូចរចា ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៦ គឺមានឈ្មោះ និងស្នាមម្រាមដៃកម្មកររនិយោជិតចំនួន ១៣នាក់ បានសរសេរលិខិតសូមបដិសេធ និងដកខ្លួន ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៦។ និយោជកទទួលស្គាល់ថា កម្មកររនិយោជិតជាដើមបណ្តឹងនៅសល់ចំនួន ៥នាក់ប៉ុណ្ណោះ ដោយក្នុងនោះ មានកម្មកររនិយោជិតចំនួន ៣នាក់ មានឈ្មោះនៅក្នុងបញ្ជីឈ្មោះកម្មកររនិយោជិតចំនួន ១៦នាក់ និងកម្មកររនិយោជិតចំនួន ២នាក់ទៀត មានវត្តមានក្នុងសវនាការ។

មុនពិចារណាលើចំណុចវិវាទនៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាទាក់ទងនឹងកម្មកររនិយោជិតដែលជាដើមបណ្តឹងជាមុនសិន។

ប្រការ ១៩ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា ៖ *"ភាគីវិវាទអាចមកបង្ហាញខ្លួន នៅចំពោះមុខក្រុមអាជ្ញាកណ្តាលដោយផ្ទាល់ខ្លួន ឬដោយមានអ្នកអម ឬអ្នកតំណាងដោយមេធាវីដែលជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឬដោយបុគ្គលផ្សេងទៀត ដែលទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីភាគីនោះ។"*

យោងតាមប្រការ ១៩ នៃប្រកាសលេខ ០៩៩ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានឃើញថា ពាក្យ *"ទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរ"* មានន័យថា ភាគីវិវាទអាចឱ្យបុគ្គលផ្សេងតំណាងឱ្យខ្លួន ក្នុងការដោះស្រាយវិវាទការងារនៅចំពោះមុខក្រុមអាជ្ញាកណ្តាលបាន លុះត្រាតែបុគ្គលនោះទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរ ដើម្បីមកធ្វើជាតំណាងរបស់ភាគីវិវាទ។ *(សូមមើលសេចក្តីប្រកាសអាជ្ញាកណ្តាលស្តីពី*

១៦១/០៩-សិប្បកម្ម ព្រែកត្រែង, លេខ ៤៣/១០-ម៉ឺង ជឿន, លេខ ១៤៤/១២-អ៊ី ហ្គាមេន និងលេខ ១២០/១៥-ក័រហ្វិក គ្រោស៍ ប្រាយវេត ខូអិលធីឌី)

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របទៅនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

យោងតាមឯកសារថតចម្លងបញ្ជីឈ្មោះកម្មកររនិយោជិត ដែលបានផ្តិតស្នាមម្រាមដៃទាមទារនៅក្នុងលិខិតស្នើសុំ និងចាត់តាំងប្រតិភូចរចា ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៦ ដែលភ្ជាប់ជាមួយរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ប្រ្គេត ញូ វែង ហ្គាម៉ុន (ខេមបូឌា) ឯ.ក មានបញ្ជីឈ្មោះ និងស្នាមម្រាមដៃកម្មកររនិយោជិតសរុបចំនួន ៦៤នាក់។ យ៉ាងណាមិញ នៅក្នុងសវនាការ កាគីកម្មកររនិយោជិតបានបញ្ជាក់ថា ការទាមទារនេះ គឺសម្រាប់កម្មកររនិយោជិតសរុបចំនួន ១៨នាក់ ដោយក្នុងនោះមានកម្មកររនិយោជិតចំនួន ១៦នាក់ បានផ្តិតស្នាមម្រាមដៃនៅក្នុងលិខិតស្នើសុំ និងចាត់តាំងប្រតិភូចរចា ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៦ និងកម្មកររនិយោជិតចំនួន ២នាក់ទៀត បានមកចូលរួមសវនាការ។

ផ្អែកតាមឯកសារថតចម្លងរបស់កម្មកររនិយោជិត ដែលបានដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២ ខែមេសា ឆ្នាំ២០២៦ ស្តីពីបញ្ជីឈ្មោះកម្មកររនិយោជិតចំនួន ១៦នាក់ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា មានឈ្មោះ និងស្នាមម្រាមដៃរបស់កម្មកររនិយោជិតនៅក្នុងលិខិតស្នើសុំ និងចាត់តាំងប្រតិភូចរចាខាងលើនេះ ចំនួន ១៥នាក់តែប៉ុណ្ណោះ ពោលគឺមិនមានកម្មកររនិយោជិតឈ្មោះ ង ល នោះទេ។ ជាមួយគ្នានេះ កម្មកររនិយោជិតចំនួន ២នាក់ ដែលមានវត្តមាននៅក្នុងសវនាការ គឺឈ្មោះ ផសវ អត្តលេខ និងឈ្មោះ ហបហ អត្តលេខ ក៏មានឈ្មោះ និងស្នាមម្រាមដៃនៅក្នុងលិខិតស្នើសុំ និងចាត់តាំងប្រតិភូចរចា ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៦ ផងដែរ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា កម្មកររនិយោជិតដែលជាដើមបណ្តឹងក្នុងចំណុចវិវាទនេះសរុបចំនួន ១៧នាក់តែប៉ុណ្ណោះ។

ទោះបីជាយ៉ាងនេះក៏ដោយ ផ្អែកតាមឯកសារកេស្តុតាងរបស់និយោជកបានដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីលិខិតសូមបដិសេធ និងដកខ្លួន ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៦ ដែលបានភ្ជាប់ជាមួយឈ្មោះ និងស្នាមម្រាមដៃរបស់កម្មកររនិយោជិតសរុបចំនួន ៥៣នាក់ បានបញ្ជាក់ថា មានឈ្មោះ និងស្នាមម្រាមដៃរបស់កម្មកររនិយោជិតជាដើមបណ្តឹងចំនួន ១៣នាក់ ដែលមានឈ្មោះក្នុងលិខិតស្នើសុំ និងចាត់តាំងប្រតិភូចរចា ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៦ ក៏បានសរសេរលិខិតសូមបដិសេធ និងដកខ្លួនខាងលើផងដែរ។ យ៉ាងណាមិញ នៅក្នុងសវនាការ កាគីកម្មកររនិយោជិតបានបដិសេធចំពោះលិខិតសូមបដិសេធ និងដកខ្លួននេះថា លិខិតនេះបានធ្វើឡើងដោយសារកម្មកររនិយោជិតមានការភ័យខ្លាចចំពោះការប្តឹងប្រធានផ្នែករបស់ពួកគាត់។ ម្យ៉ាងទៀត លិខិតសូមបដិសេធ និងដកខ្លួនខាងលើ គឺមានខ្លឹមសារមិនច្បាស់លាស់ដែលអាចភាន់ច្រឡំ និងមិនបានបញ្ជាក់ច្បាស់ថាជាស្នាមម្រាមដៃរបស់កម្មកររនិយោជិតដែលបានប្តឹងបដិសេធនឹងចំណុចវិវាទនេះនោះទេ។

នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីដែលធ្វើការអះអាង ឬចោទប្រកាន់ គឺមានបន្ទុកកស្តុតាង។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៧៩/០៥-អេវើរប្រ៊ីន, លេខ ១០១/០៨-ដឺឌីអ៊ីម ហេតុផលនៃចំណុចវិវាទទី១ និងទី២, លេខ ១៦៨/០៩-ទឹកថ្លា ផ្លាហ្សា ហេតុផលនៃចំណុចវិវាទទី២, លេខ ១១៥/១០-ជី-ហ្គម៉ូស ហេតុផលនៃចំណុចវិវាទទី១៨, លេខ ១៤៨/១១-ជាយ-ឃ្យុង-ន៊ីង្គាលេខ ២៧៦/១៥-មិត្តភាព ហ្គាមិន ហេតុផលនៃចំណុចវិវាទទី១)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ បានបដិសេធការទាមទារ ឬច្រានចោលភាគីអះអាងរបស់ភាគីវិវាទ ប្រសិនបើភាគីដែលធ្វើការទាមទារ ឬធ្វើការអះអាងនោះ មិនមានមូលដ្ឋានគ្រប់គ្រាន់បញ្ជាក់

ជាក់លាក់ ដើម្បីគាំទ្រនូវការទាមទារ ឬការអះអាងរបស់ខ្លួន។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៦៣/០៤-សាញ វែល ហេតុផលនៃចំណុចវិវាទទី៤, លេខ ៩៩/០៦-សៅធ៍បាយ ហេតុផលនៃចំណុចវិវាទទី៥, លេខ ៣៣/០៧-ហ្គោលហ្វេម ហេតុផលនៃចំណុចវិវាទទី៤, លេខ ៥១/០៧-ហ្គោលហ្វេម ហេតុផលនៃចំណុចវិវាទទី៣, និងលេខ ០៣២/១៦-អ៊ីធើនិធី ក្លូបិល ស្ព័តធីង (ខេមបូឌា) ខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី១)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

ករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ក្រៅពីការអះអាងនៅក្នុងសវនាការ ភាគីកម្មករនិយោជិតមិនបានផ្តល់ភស្តុតាងណាមួយ ដើម្បីគាំទ្រអំណះអំណាងដែលថា ការធ្វើលិខិតសូមបដិសេធ និងដកខ្លួន ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៦ ខាងលើ បានធ្វើឡើងដោយសារការភ័យខ្លាចរបស់កម្មករនិយោជិត និងមានខ្លឹមសារមិនច្បាស់លាស់យ៉ាងដូចម្តេចនោះទេ។ ម្យ៉ាងទៀត ភាគីកម្មករនិយោជិតក៏មិនបានផ្តល់ភស្តុតាងណាមួយបញ្ជាក់ថា កម្មករនិយោជិតដែលមានឈ្មោះនៅក្នុងលិខិតសូមបដិសេធ និងដកខ្លួននៅតែបន្តទាមទារទៀតនោះឡើយ។

យោងតាមលិខិតសូមបដិសេធ និងដកខ្លួន ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៦ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ក្នុងចំណោមកម្មករនិយោជិតចំនួន ៥៣នាក់ ក៏មានឈ្មោះ និងស្នាមម្រាមដៃកម្មករនិយោជិតចំនួន ១៣នាក់ ដែលមានឈ្មោះក្នុងលិខិតស្នើសុំ និងចាត់តាំងប្រតិភូចរចា ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៦ រួមមាន

១.	អសផ	, ២.	វធរ	៣.	មសន
៤.	អផល	៥.	អសខ	, ៦.	សសព
៧.	កផល	, ៨.		៩.	វស
១០.	បសខ	,១១.	បសម	១២.	ងព

និង ១៣. ពចរ ។ ដោយហេតុថា ការបកស្រាយអំពីដើមបណ្តឹងខាងលើ គឺមានកម្មករនិយោជិតដែលជាដើមបណ្តឹងចំនួន ១៧នាក់តែប៉ុណ្ណោះ ហើយក្រុមប្រឹក្សាអាជ្ញាកណ្តាលបានរកឃើញថា ក្នុងចំណោមកម្មករនិយោជិតដែលជាដើមបណ្តឹងចំនួន ១៧នាក់នេះ មានកម្មករនិយោជិតចំនួន ១៣នាក់ បានស្នើសុំបដិសេធ និងដកខ្លួនតាមរយៈលិខិតខាងលើ។ ហេតុនេះ កម្មករនិយោជិតចំនួន ១៣នាក់ ខាងលើ គឺបានដកខ្លួនចេញពីចំណុចវិវាទនេះហើយ។

យោងតាមប្រការ ១៩ នៃប្រកាសលេខ ០៩៩ សកបយ. និងការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិតចំនួន ១៣នាក់នេះ គឺមិនមែនជាដើមបណ្តឹងនៅក្នុងចំណុចវិវាទនេះទៀតនោះទេ។ ហេតុនេះ កម្មករនិយោជិតដែលជាដើមបណ្តឹងនៅក្នុងចំណុចវិវាទនេះនៅសល់ចំនួន ៤នាក់ តែប៉ុណ្ណោះ រួមមាន ១. សរថ ២. មស

៣.	ផសវ	៤.	ហបហ	។ *(សូមមើលឧបសម្ព័ន្ធ បញ្ជីឈ្មោះ កម្មករនិយោជិតដែលបានផ្តិតស្នាមម្រាមដៃនៅក្នុងលិខិតស្នើសុំ និងចាត់តាំងប្រតិភូចរចា ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៦ និងបញ្ជីឈ្មោះកម្មករនិយោជិត)*

ជាបន្ត ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចសងរំលឹកការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលចំនួន ២ថ្ងៃ គឺនៅថ្ងៃទី៥ និងទី៦ ខែមករា ឆ្នាំ២០២៦ ជូនកម្មករនិយោជិតចំនួន ៤នាក់វិញដែរ ឬទេ ?

យោងតាមមាត្រា ១៧០ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ ចែងថា ៖ *"តាមគោលការណ៍ ការឈប់សំរាកប្រចាំឆ្នាំ ត្រូវអនុញ្ញាត ក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរ លើកលែងតែមានកិច្ចព្រមព្រៀងលើពេលណាមួយទៀត រវាងនិយោជក និង កម្មករនិយោជិត។ ក្នុងករណីនេះ និយោជកត្រូវតែជូនដំណឹងជាមុនទៅអធិការកិច្ចការងារអំពីការដែលបានស្រុះស្រួលគ្នានោះ។*

ក្នុងករណីទាំងអស់ ដែលការឈប់សំរាកប្រចាំឆ្នាំមានប្រាក់ឈ្នួល មានចិរវេលាច្រើនជាងដប់ប្រាំថ្ងៃនោះ និយោជកត្រូវមានសិទ្ធិទុកថ្ងៃឈប់សំរាក ដែលនៅសល់ទាំងប៉ុន្មានឱ្យឈប់ក្នុងពេលណាមួយផ្សេងទៀតក្នុងឆ្នាំនោះ លើកលែងតែចំពោះការឈប់សំរាកនៃក្មេង និងកូនជាងដែលមានអាយុតិចជាង ១៨ ឆ្នាំ"។

នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ៖ *"មាត្រា ១៧០ នៃច្បាប់ស្តីពីការងារខាងលើនេះ មានន័យថា ការប្រើប្រាស់ការឈប់សម្រាកប្រចាំឆ្នាំរបស់កម្មករនិយោជិត និយោជកត្រូវអនុញ្ញាតឱ្យឈប់នៅឱកាសបុណ្យចូលឆ្នាំខ្មែរ និងប្រើប្រាស់ការឈប់សម្រាកប្រចាំឆ្នាំរបស់កម្មករនិយោជិតនៅពេលណាមួយក្រៅពីឱកាសបុណ្យចូលឆ្នាំខ្មែរបាន ទៅតាមកិច្ចព្រមព្រៀង ដែលធ្វើឡើងដោយភាគីកម្មករនិយោជិត និងភាគីនិយោជក"។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ២១/០៥-ស៊ីណូមេក ហេតុផលនៃចំណុចវិវាទទី២, លេខ ៨១/០៧-ស៊ុប ព្រីម ហេតុផលនៃចំណុចវិវាទទី១, លេខ ១២៣/០៩-ស៊ូតវ៉ែ ហេតុផលនៃចំណុចវិវាទទី២, លេខ ០០៣/១៣-តៃ រ៉ាង ព្រីនធីង ហេតុផលនៃចំណុចវិវាទទី២, លេខ ០២៩/១៦ ហ្ស្រេត អននើរ ថេកស្តាយ ហ្វេកធើរី លីមីធីត ហេតុផលនៃចំណុចវិវាទទី៣, លេខ ០២៥/២១-ខេន ស្ព័ថត ស៊ូ ហេតុផលនៃចំណុចវិវាទទី២, លេខ ០០៦/២២-ស្តាឡៃប៍ អឺកែរឹល ម៉ែនូហ្វេកធឺរីង ហេតុផលនៃចំណុចវិវាទទី១, និងលេខ ០២១/២២-សាន់ សឺខល ហ្គាមេន ង.ក ហេតុផលនៃចំណុចវិវាទទី៥)*

បន្ថែមលើសពីនេះទៀត នៅក្នុងសំណុំរឿងលេខ ៥៣/០៤- ហេតុផលនៃចំណុចវិវាទទី២ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ៖ *"និយោជកមិនអាចយកថ្ងៃឈប់សម្រាកប្រចាំឆ្នាំរបស់កម្មករនិយោជិត មកប្រើប្រាស់សំរាប់ពេលដែលក្រុមហ៊ុនអត់ការងារឱ្យកម្មករនិយោជិតធ្វើឡើយ។ និយោជកត្រូវកំណត់នូវការឈប់ឱ្យបានច្បាស់លាស់បើការឈប់នោះមានអំឡុងពេលខុសពីថ្ងៃចូលឆ្នាំខ្មែរ។ ចំពោះការផ្លាស់ប្តូរត្រូវមានការយល់ព្រមពីភាគីនិយោជិត និងបានរាយការណ៍ទៅអធិការកិច្ចការងារជ្រាបមុនការអនុវត្តន៍។" (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៤៥/០៥-ប៊ី អែន អិន ហេតុផលនៃចំណុចវិវាទទី២, លេខ ១៨១/១១-ណាក់ហ្គេត តេចស្តាយ ហេតុផលនៃចំណុចវិវាទទី២ និងទី៣, លេខ ០៣/១៣ ហេតុផលនៃចំណុចវិវាទទី២ និងលេខ ១៣០/១៦-ខេម តេកាង ស្ព័តថេក ខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី២)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ ក៏យល់ស្របតាមការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

ក្នុងករណីនេះ ភាគីទាំងពីរទទួលស្គាល់ថា នៅថ្ងៃទី៣ ឬទី៤ ខែមករា ឆ្នាំ២០២៦ និយោជកបានប្រជុំជាមួយតំណាងកម្មករនិយោជិត និងប្រធានផ្នែកអំពីការអនុញ្ញាតឱ្យប្រើប្រាស់ការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលចំនួន ២ថ្ងៃ គឺថ្ងៃទី៥ និងទី៦ ខែមករា ឆ្នាំ២០២៦ នៅពេលនិយោជកមិនមានការងារឱ្យកម្មករនិយោជិតធ្វើ ហើយប្រធានផ្នែក និងតំណាងកម្មករនិយោជិត ក៏បានប្រជុំជូនដំណឹងបន្តទៅកម្មករនិយោជិតតាមផ្នែករៀងៗខ្លួន។ ជាមួយគ្នានេះ ភាគីនិយោជកបានអះអាងថា មិនមានកម្មករនិយោជិតណាម្នាក់តវ៉ាអំពីការឈប់សម្រាកដោយប្រើប្រាស់ការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលនោះទេ ហើយនិយោជកអនុញ្ញាតឱ្យកម្មករនិយោជិតប្រើប្រាស់ការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលនេះ មុនពេលដែលកម្មករនិយោជិតធ្វើការបានមួយឆ្នាំ គឺជាការអនុវត្តប្រសើរជាងច្បាប់។ ហេតុនេះ ការអនុញ្ញាតឱ្យកម្មករនិយោជិតឈប់សម្រាកដោយ

ប្រើប្រាស់ការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល នៅពេលដែលនិយោជកមិនមានការងារឱ្យកម្មករនិយោជិតធ្វើ គឺជាសិទ្ធិចាត់ចែងរបស់និយោជក។ យ៉ាងណាមិញ ភាគីកម្មកនិយោជិតអះអាងថា ការប្រជុំនេះបានធ្វើឡើងនៅចុងម៉ោងធ្វើការរបស់កម្មកនិយោជិត ដែលធ្វើឱ្យពួកគាត់មិនមានពេលក្នុងការគេរ៉ាឱ្យមានដំណោះស្រាយ។

យោងតាមអំណះអំណាងខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ថ្វីត្បិតតែការអនុវត្តរបស់និយោជកឱ្យកម្មកនិយោជិតប្រើប្រាស់ការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល មុនពេលកម្មករនិយោជិតធ្វើការបានមួយឆ្នាំ មានលក្ខណៈប្រសើរជាងច្បាប់ក៏ដោយ ក៏មិនមានន័យថា និយោជកមានសិទ្ធិចាត់ចែងឱ្យកម្មកនិយោជិតឈប់សម្រាកដោយប្រើប្រាស់ការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល នៅពេលដែលនិយោជកមិនមានការងារឱ្យកម្មកនិយោជិតធ្វើនោះឡើយ។ ម្យ៉ាងទៀត ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យើញថា ភាគីនិយោជកមិនបានបង្ហាញភស្តុតាងណាមួយ អំពីការព្រមព្រៀងពីកម្មកនិយោជិតក្នុងការឈប់សម្រាកចំនួន ២ថ្ងៃ គឺនៅថ្ងៃទី៥ និងទី៦ ខែមករា ឆ្នាំ២០២៦ ដោយប្រើប្រាស់ការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលនោះទេ ពោលគឺនិយោជកគ្រាន់តែបានប្រជុំជូនដំណឹងបន្តតាមរយៈប្រធានផ្នែក និងតំណាងកម្មកនិយោជិត ទៅកាន់កម្មកនិយោជិតតាមផ្នែករៀងៗខ្លួនដោយផ្ទាល់មាត់តែប៉ុណ្ណោះ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការដែលនិយោជកចាត់ចែងឱ្យកម្មកនិយោជិតឈប់សម្រាកដោយប្រើប្រាស់ការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល នៅពេលដែលនិយោជកមិនមានការងារឱ្យកម្មកនិយោជិតធ្វើដោយមិនមានការព្រមព្រៀងណាមួយពីកម្មកនិយោជិតសាមី គឺជាការអនុវត្តមួយដែលមិនស្របតាមមាត្រា ១៧០ នៃច្បាប់ស្តីពីការងារនោះទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកត្រូវសងរំលឹកការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលចំនួន ២ថ្ងៃ គឺនៅថ្ងៃទី៥ និងទី៦ ខែមករា ឆ្នាំ២០២៦ ដែលនិយោជកមិនមានការងារឱ្យកម្មកនិយោជិតធ្វើ ជូនកម្មកនិយោជិតទាំង ៤នាក់វិញ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបង្គាប់ឱ្យនិយោជកសងរំលឹកការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលចំនួន ២ថ្ងៃ គឺនៅថ្ងៃទី៥ និងទី៦ ខែមករា ឆ្នាំ២០២៦ ដែលនិយោជកមិនមានការងារឱ្យកម្មកនិយោជិតធ្វើ ជូនកម្មកនិយោជិតចំនួន ៤នាក់ រួមមាន ១.
២. ៣. និង ៤. ។

យោងតាមអង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

សម្រេច និង បង្គាប់

ចំណុចវិវាទ ៖

- បង្គាប់ឱ្យនិយោជកសងរំលឹកការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលចំនួន ២ថ្ងៃ គឺនៅថ្ងៃទី៥ និងទី៦ ខែមករា ឆ្នាំ២០២៦ ដែលនិយោជកមិនមានការងារឱ្យកម្មកនិយោជិតធ្វើ ជូនកម្មកនិយោជិត ចំនួន ៤នាក់ រួមមាន ១. ,២.
៣. និង ៤.

THE ARBITRATION COUNCIL

ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច

សេចក្តីបង្គាប់នេះ នឹងក្លាយជាស្តាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ ចំនួន ០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលជ្រាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ។

ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **សេង ឆួចហ៊ុន**

ហត្ថលេខា ៖ ----------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីតំណាងនិយោជិត ៖

ឈ្មោះ ៖ **លឹម សុវណ្ណា**

ហត្ថលេខា ៖----------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ប៉ែន ប៊ុនឈា**

ហត្ថលេខា ៖ ----------

ទាយកដ្ឋានវិវាទការងារ
សំណុំរឿង វិវាទការងាររួមលេខ: 020/26
ចូលថ្ងៃទី 18 ខែ 02 ឆ្នាំ 2026

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទាយកដ្ឋានវិវាទការងារ
ចូល
ថ្ងៃទី 18 ខែ 02 ឆ្នាំ 2026
ម៉ោង 15:00
លេខ: 510 ឧ/ឆ/ឯ

លិខិតស្នើសុំ និងចាត់តាំងប្រតិភូចរចា

យើងខ្ញុំជាថ្នាក់ដឹកនាំ សហជីពការងារដើម្បីកម្ពុជា និងកម្មករនិយោជិតនៃក្រុមហ៊ុន ហ្ជ្រេត ញ្ញ រីង ហ្គាមុិន (ខេមបូឌា) ង.ក មានអាសយដ្ឋានភូមិយុលចេក ឃុំជីខ្ឋា ស្រុកទ្រាំង ខេត្តតាកែវ ។

សូមគោរពជូន

លោកប្រធាននាយកដ្ឋានវិវាទការងារ

កម្មវត្ថុ: ស្នើសុំ លោកប្រធាន មេត្តាជួយសម្របសម្រួល និងដោះស្រាយនូវលក្ខខណ្ឌការងាររបស់កម្មករនិយោជិត ។

យោង: - វិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវ: លេខ០៥១/ ២៦ ក.ប/វ.ប.រ.ក ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវ: ចុះថ្ងៃទី ២ ខែកុម្ភ: ឆ្នាំ២០២៦

តបតាមកម្មវត្ថុ និងយោងខាងលើសូម លោកប្រធាន មេត្តាជួយសម្របសម្រួលនិងដោះស្រាយនូវលក្ខខណ្ឌការងារជូនកម្មករនិយោជិតទាំងអស់គ្នាដូចខាងក្រោម:

1-/ ចំពោះកម្មករនិយោជិត ដល់កិច្ចសន្យាការងារ ៣ខែម្តង សុំឱ្យក្រុមហ៊ុនគិតទូទាត់ប្រាក់ជួសការឈប់សម្រាកប្រចាំឆ្នាំ (បំណាច់ឆ្នាំ) បូកជាមួយប្រាក់បំណាច់កិច្ចសន្យា ៥% ឱ្យបានរួចរាល់ ក្នុង ១វគ្គៗ ។

2-/ ករណីកម្មករនិយោជិត សុំឈប់ពីការងារ សុំឱ្យក្រុមហ៊ុនគិតទូទាត់ប្រាក់បំណាច់ឆ្នាំ និងប្រាក់បំណាច់កិច្ចសន្យាការងារ ៥% ជូនគាត់ទាំងអស់ ឱ្យបានត្រឹមត្រូវតាមច្បាប់ស្តីពីការងារ (បច្ចុប្បន្នក្រុមហ៊ុនគិតឱ្យ តែប្រាក់ខែចុងក្រោយប៉ុន្មានថ្ងៃទេ) ។

3-/ សុំ កុំឱ្យក្រុមហ៊ុនបង្ខំកម្មករនិយោជិត ធ្វើការឱ្យគ្រប់ចំនួនតាមផែនការដែលដាក់ឱ្យធ្វើ ហួសពីកំលាំង របស់គាត់ ។

4-/ សុំឱ្យក្រុមហ៊ុនអនុវត្តការបន្ថែមម៉ោងមិនឱ្យលើស ពី ២ម៉ោង ក្នុង១ថ្ងៃ (ត្រឹមម៉ោង ៦) ឱ្យស្របតាមច្បាប់ បច្ចុប្បន្នបង្ខំកម្មករនិយោជិត ថែមម៉ោងដល់ម៉ោង ៩ ទៅដល់ម៉ោង ១០ យប់ ។

5-/ ក្នុងករណីកម្មករនិយោជិត ស្ម័គ្រចិត្តធ្វើការថែមម៉ោងនៅថ្ងៃអាទិត្យ ឬថ្ងៃបុណ្យ សុំឱ្យក្រុមហ៊ុនបើកលុយនៅថ្ងៃហ្នឹងតែម្តង ឬនៅថ្ងៃស្អែក ដើម្បីងាយស្រួលពួកគាត់យកទៅដោះស្រាយការចំណាយក្នុងជីវភាពប្រចាំថ្ងៃ ។

6-/ សុំឱ្យក្រុមហ៊ុន បើកលុយថ្លៃបាយបន្ថែមម៉ោង ជូនកម្មករនិយោជិត ក្នុង ១អាទិត្យម្តង ។

7-/សុំឱ្យក្រុមហ៊ុន បញ្ឈប់សកម្មភាព ការរើសអើង ចំពោះសហជីពការងារដើម្បីកម្ពុជា ដែលបានបង្កើតឡើងស្របច្បាប់ តទៅទៀត ព្រោះបច្ចុប្បន្នផ្នែករដ្ឋបាល និងប្រធានៗតាមផ្នែក កំពង់គំរាម បំភ័យ កម្មករនិយោជិតថា បើកម្មករនិយោជិតណា ចូលសហជីពខាងក្រៅ (សហជីពការងារដើម្បីកម្ពុជា) គឺក្រុមហ៊ុននឹងបញ្ឈប់ពីការងារ ឬ ដល់កុងត្រា ឈប់បន្តឱ្យធ្វើការទៀតហើយ ។

8-/សុំឱ្យ ថៅកែ ឬ នាយកក្រុមហ៊ុន ណែនាំបុគ្គលិកផ្នែកប្រធានរដ្ឋបាល បញ្ឈប់សកម្មភាព បង្កំកម្មករនិយោជិត ឱ្យផ្តិតមេដៃ ចូលសមាជិកសហជីព (ខាងក្រុមហ៊ុន) ឱ្យរួចរាល់សិន មុនពេលចូលធ្វើការថ្ងៃដំបូង ។

9-/សុំឱ្យ ថៅកែ ឬ នាយកក្រុមហ៊ុន ជួយធ្វើការណែនាំ ជនជាតិចិន ភេប្រុស គ្រប់គ្រងផ្នែកផលិតកម្ម ឈ្មោះក្រៅហៅ ត ង និងជនជាតិចិន ភេទស្រី គ្រប់គ្រងផ្នែក ដេរ កុំឱ្យហៅកម្មករនិយោជិតដែលចូលសហជីពការងារដើម្បីកម្ពុជា មកសួរនាំ ។

10-/ សុំឱ្យក្រុមហ៊ុនដកបុគ្គលិកផ្នែកជំនួយការរដ្ឋបាលឈ្មោះ មសក ភេទស្រី ចេញពីក្រុមហ៊ុន ព្រោះបុគ្គលិរូបនេះ ប្រើពាក្យសំដី និងកាយវិការមិនសមរម្យ (គ្មានសុជីវធម៌) មកលើកម្មករនិយោជិត និងបញ្ឈប់កម្មករនិយោជិតពីការងារ ដោយគ្មានមូលហេតុត្រឹមត្រូវ ជាពិសេសគំរាម កម្មករនិយោជិតមិនឱ្យចូលសមាជិកសហជីពខាងក្រៅ (សហជីពការងារដើម្បីកម្ពុជា) និងធ្លាប ផ្តល់ជាលុយ ឱ្យកម្មករនិយោជិត ជាផ្ទូរ ការលាលែងចេញពីសហជីពការងារដើម្បីកម្ពុជា ឬលាលែងចេញពីការងារតែម្តង ។

THE ARBITRATION COUNCIL